**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសាធារណការ និងដឹកជញ្ជូន**

លេខ:......០១៩........[illegible]...សក

រាជធានីភ្នំពេញ, ថ្ងៃទី...២៤...ខែ...[illegible]...ឆ្នាំ២០១៦

# សារាចរណែនាំ
## ស្តីពី
## ការបញ្ជាក់លើទម្ងន់ផ្ទុកកុងតេន័រសរុប

ដើម្បីអនុវត្តការបញ្ជាក់ទម្ងន់ផ្ទុកកុងតេន័រ នៅមុនពេលផ្ទុកចូលនាវា សម្រាប់ការនាំចេញ ស្របតាមលក្ខខណ្ឌដូចមានចែងនៅក្នុងអនុសញ្ញាអន្តរជាតិ ស្តីពីសុវត្ថិភាពនៃអាយុជីវិតនៅសមុទ្ររបស់អង្គការនាវាចរណ៍សមុទ្រអន្តរជាតិដែលនឹងចូលជាធរមាននៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៦ ក្រសួងសាធារណការនិងដឹកជញ្ជូន សូមធ្វើការណែនាំដល់អ្នកផ្ញើទំនិញ អ្នកដឹកទំនិញ ឬក្រុមហ៊ុននាវា កំពង់ផែ និងអ្នកផ្តល់សេវា ពាក់ព័ន្ធដទៃទៀត ដូចខាងក្រោម ៖

១- ការបញ្ជាក់លើទម្ងន់ផ្ទុកកុងតេន័រ សម្រាប់ផ្ទុកចូលនាវា ជាបន្ទុករបស់អ្នកផ្ញើទំនិញ។

២- អ្នកផ្ញើទំនិញ ឬ តំណាងស្របច្បាប់ ត្រូវផ្តល់ឯកសារបញ្ជាក់ទម្ងន់ផ្ទុកកុងតេន័រគ្រប់គ្រាន់ ទៅក្រុមហ៊ុននាវា ឬតំណាងស្របច្បាប់នៃក្រុមហ៊ុននាវា និងកំពង់ផែ ឬតំណាងស្របច្បាប់នៃកំពង់ផែ ដើម្បីផ្ទុកទំនិញចូលទៅក្នុងនាវា។ ឯកសារបញ្ជាក់ទម្ងន់ផ្ទុកកុងតេន័រ ត្រូវបញ្ជាក់អំពីចំណុចអប្បបរមា ដូចខាងក្រោម៖

- លេខកក់ (Booking Number) និងកាលបរិច្ឆេទ
- ឈ្មោះ អាសយដ្ឋាន របស់អ្នកផ្ញើទំនិញ
- លេខកុងតេន័រ ទម្ងន់សំបកកុងតេន័រ ទម្ងន់ទំនិញ និងទម្ងន់កុងតេន័រសរុប។

ទម្រង់នៃឯកសារបញ្ជាក់ទម្ងន់ផ្ទុកកុងតេន័រមានភ្ជាប់នៅក្នុង **ឧបសម្ព័ន្ធ**។

អ្នកផ្ញើទំនិញ អាចប្រើប្រាស់ទម្រង់នៃឯកសារបញ្ជាក់ទម្ងន់ផ្ទុកកុងតេន័រផ្សេងទៀត អាស្រ័យដោយមានការឯកភាពរវាងក្រុមហ៊ុននាវានិងកំពង់ផែ។

ឯកសារបញ្ជាក់ទម្ងន់ផ្ទុកកុងតេន័រ ត្រូវចុះហត្ថលេខាដោយអ្នកផ្ញើទំនិញ ឬ តំណាងស្របច្បាប់នៃអ្នកផ្ញើទំនិញ។ ការចុះហត្ថលេខា អាចត្រូវបានធ្វើតាមអេឡិចត្រូនិច ឬ អាចត្រូវបានជំនួសដោយឈ្មោះជាអក្សរធំរបស់អ្នកដែលបានទទួលសិទ្ធិចុះហត្ថលេខា។

ក្នុងករណីដែលកុងតេន័រមានផ្ទុកទំនិញច្រើនម្ចាស់ ភ្នាក់ងារបញ្ជូនទំនិញបន្ត (Forwarder or Consolidator) ត្រូវចុះហត្ថលេខានៅលើឯកសារបញ្ជាក់ទម្ងន់ផ្ទុកកុងតេន័រ។ ក្នុងករណីដែលមានការផ្ទេរផ្ទុកកុងតេន័រទំនិញពីនាវាមួយទៅនាវាមួយទៀត អ្នកផ្ញើទំនិញដែលមានឈ្មោះនៅក្នុងបណ្ណដឹកជញ្ជូន (Bill of Lading) គឺជាអ្នកទទួលខុសត្រូវចំពោះភាពត្រឹមត្រូវនៃការពិនិត្យផ្ទៀងផ្ទាត់បញ្ជាក់ទម្ងន់ទំនិញទាំងការផ្ទុក និងផ្ទេរកុងតេន័រ។

៣- កុងតេន័រដែលមិនមានឯកសារបញ្ជាក់ទម្ងន់ផ្ទុក នឹងមិនត្រូវបានអនុញ្ញាតអោយផ្ទុកចូលនាវាឡើយ។ អ្នកផ្ញើទំនិញត្រូវផ្ញើជាមុនទៅក្រុមហ៊ុននាវា ឬ តំណាងស្របច្បាប់នៃក្រុមហ៊ុននាវានិងកំពង់ផែនូវឯកសារបញ្ជាក់ទម្ងន់ផ្ទុកកុងតេន័រ សម្រាប់ការរៀបចំផែនការផ្ទុកកុងតេន័រលើនាវាឲ្យបានត្រឹមត្រូវ។

ក្រុមហ៊ុននាវា និងកំពង់ផែ ត្រូវធានាថាកុងតេន័រនីមួយៗ នៅមុនពេលផ្ទុកចូលក្នុងនាវាត្រូវមាននៅក្នុងឯកសារបញ្ជាក់ទម្ងន់ផ្ទុកកុងតេន័រ។

ក្រុមហ៊ុននាវា និងកំពង់ផែត្រូវធ្វើការកំណត់អំពីពេលវេលាសមស្រប និងរបៀបផ្ញើជាមុននូវឯកសារបញ្ជាក់ទម្ងន់ផ្ទុកកុងតេន័រ។

ក្នុងករណីដែលកុងតេន័របានទៅដល់កំពង់ផែ ដោយពុំមានឯកសារទម្ងន់ផ្ទុកកុងតេន័រមេបញ្ជាការនាវា ឬ តំណាងស្របច្បាប់ក្រុមហ៊ុននាវា និងកំពង់ផែ ឬ តំណាងស្របច្បាប់កំពង់ផែត្រូវរិះរកមធ្យោបាយសម្របសម្រួលធ្វើយ៉ាងណា ដើម្បីឱ្យអ្នកផ្ញើទំនិញអាចបំពេញឯកសារទម្ងន់ផ្ទុកកុងតេន័របាន។ ក្នុងករណីនេះ ការថ្លឹងអាចធ្វើទៅបាននៅកំពង់ផែ ឬ ទីតាំងផ្តល់សេវាកម្មថ្លឹងទំនិញ ឬ នៅតាមស្ថានីយ៍ជញ្ជីង ដោយមានការឯកភាពរវាងភាគីទាំងពីរ។ កំពង់ផែ អាចធ្វើសេចក្តីណែនាំលម្អិតជម្រាបជូនអតិថិជន អំពីស្ថានភាព និងសមត្ថភាពទទួលយកដាក់ស្តែងនៅទីតាំងរបស់ខ្លួន។

ទម្ងន់សរុបកុងតេន័រទំនិញដែលទទួលបានពីការពិនិត្យផ្ទៀងផ្ទាត់នេះ នឹងត្រូវយកមកប្រើប្រាស់ សម្រាប់រៀបចំកុងតេន័រផ្ទុកចូលនាវា។

៤- ការថ្លឹងទម្ងន់ផ្ទុកកុងតេន័រ អាចធ្វើឡើងតាមរបៀបពីរយ៉ាង៖

ក- ថ្លឹងទម្ងន់កុងតេន័រសរុប បន្ទាប់ពីបានផ្ទុកទំនិញរួច

ខ- ថ្លឹងទំនិញដោយឡែក សំបកកុងតេន័រ និងវត្ថុផ្សេងៗដោយឡែក រួចបូកបញ្ចូលគ្នាបានជាទម្ងន់ផ្ទុកកុងតេន័រសរុប។ ចំពោះកញ្ចប់ទំនិញនីមួយៗ ដែលមានការបោះត្រាបញ្ជាក់ទម្ងន់ត្រឹមត្រូវ ឬចំពោះកេសទំនិញ ដែលមានការសរសេរបោះពុម្ពបញ្ជាក់ទម្ងន់ត្រឹមត្រូវនិងច្បាស់លាស់នៅលើផ្ទៃខាងក្រៅនៃកេស នោះមិនតម្រូវឲ្យមានការថ្លឹងម្តងទៀតទេនៅពេលលើកដាក់ទំនិញទាំងអស់នោះចូលទៅក្នុងកុងតេន័រ។

ការថ្លឹងទម្ងន់ផ្ទុកកុងតេន័រ ត្រូវធ្វើឡើងនៅតាមទីតាំងផ្តល់សេវាកម្មថ្លឹងទំនិញ ឬ នៅតាមស្ថានីយ៍ជញ្ជីង ដោយជញ្ជីងឬឧបករណ៍ថ្លឹងទម្ងន់ ដែលមានវិញ្ញាបនប័ត្រត្រួតពិនិត្យផ្ទៀងផ្ទាត់ពីមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

៥- ក្នុងករណី មានភាពខុសគ្នារវាងទំនិញដែលថ្លឹងផ្ទៀងផ្ទាត់មុនពេលបញ្ជូនទៅកំពង់ផែ និង ទម្ងន់សរុបដែលបានថ្លឹងពិនិត្យផ្ទៀងផ្ទាត់នៅកំពង់ផែ ទម្ងន់សរុបដែលផ្ទៀងផ្ទាត់នៅកំពង់ផែត្រូវចាត់ទុកជាបានការ។

៦- អ្នកផ្ញើទំនិញត្រូវធានាថា ទម្ងន់ផ្ទុកដែលបានប្រកាសនៅក្នុងឯកសារទម្ងន់ផ្ទុកកុងតេន័រពិតជាត្រឹមត្រូវ។

៧- អគ្គនាយកដ្ឋានដឹកជញ្ជូន ត្រូវសម្របសម្រួលគ្រប់ភាគីពាក់ព័ន្ធក្នុងការអនុវត្តសារាចរណែនាំនេះ ប្រកបដោយភាពរលូន និងប្រសិទ្ធភាព។

ទទួលបាននូវសារាចរណែនាំនេះ គ្រប់អ្នកផ្ញើទំនិញ អ្នកដឹកទំនិញ ឬ ក្រុមហ៊ុននាវាកំពង់ផែ និងអ្នកផ្តល់សេវាពាក់ព័ន្ធដទៃទៀត ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

Chanthol Sun

ស៊ុន ចាន់ថុល

# ឧបសម្ព័ន្ធ

# ទម្រង់នៃឯកសារបញ្ជាក់ទម្ងន់កុងតេន័រ

## Container Weight Verification

# បញ្ជាក់ទម្ងន់សរុប

**VERIFIED GROSS MASS (VGM)**

នាមករណ៍អ្នកផ្ញើទំនិញ Shipper Name (Full Name)

លេខកក់ទុកឬបណ្ណដឹកជញ្ជូន Booking or B/L Number

| លេខកុងទែន័រ<br>Container number | ប្រភេទឬទំហំកុងទែន័រ<br>Container type/size | ទម្ងន់ទំនិញសរុប<br>Cargo G.W. (KGS) | បញ្ជាក់ទម្ងន់សរុប<br>VGM (KGS)<br>(Cargo G.W. + Container Tare Weight) | វិធី<br>Method (1 or 2) |
|---|---|---|---|---|
| | | | | |

| ឈ្មោះនាវា(នៅកំពង់ផែផ្ទុកទំនិញ)<br>Vessel Name (at Port of Loading) | លេខជើងនាវា<br>Voyage Number |
|---|---|
| | |

| គោត្តនាមនិងនាមនៃអ្នកទទួលសិទ្ធ<br>Full Name of Authorized Person (in CAPITAL letter) | តួនាទី<br>Position | លេខទំនាក់ទំនង<br>Contact Number |
|---|---|---|
| | | |

ហត្ថលេខានៃអ្នកទទួលសិទ្ធ Authorized Signature

យើងខ្ញុំសូមបញ្ជាក់ថាទម្ងន់ទាំងអស់ដូចមានក្នុងការប្រកាសខាងលើពិតជាត្រឹមត្រូវប្រាកដមែន។
យើងខ្ញុំសូមបញ្ជាក់ថាជញ្ជីងដែលបានប្រើប្រាស់សម្រាប់ការថ្លឹងទម្ងន់ទំនិញសម្រាប់ផ្ញើតាមនាវានេះពិតជាបាន
បញ្ជាក់និងត្រួតពិនិត្យតាមការតម្រូវរបស់អាជ្ញាធរមានសមត្ថកិច្ច។ ការបញ្ជាក់នេះអាចបង្ហាញជូនបានតាមការស្នើសុំ។

We hereby certify the weights as decalared above to be true and accurate. We certify the scale used for weighting this shipment has been certified and inspected as required by local authorities. Verification is available upon request.

កាលបរិច្ឆេទ Date (dd/mm/yy)

---


# បញ្ជាក់ទម្ងន់សរុប

**VERIFIED GROSS MASS (VGM)**

នាមករណ៍អ្នកផ្ញើទំនិញ Shipper Name (Full Name)

លេខកក់ទុកឬបណ្ណដឹកជញ្ជូន Booking or B/L Number

| លេខកុងទែន័រ<br>Container number | ប្រភេទឬទំហំកុងទែន័រ<br>Container type/size | ទម្ងន់ទំនិញសរុប<br>Cargo G.W. (KGS) | បញ្ជាក់ទម្ងន់សរុប<br>VGM (KGS)<br>(Cargo G.W. + Container Tare Weight) | វិធី<br>Method (1 or 2) |
|---|---|---|---|---|
| | | | | |

| ឈ្មោះនាវា(នៅកំពង់ផែផ្ទុកទំនិញ)<br>Vessel Name (at Port of Loading) | លេខជើងនាវា<br>Voyage Number |
|---|---|
| | |

| គោត្តនាមនិងនាមនៃអ្នកទទួលសិទ្ធ<br>Full Name of Authorized Person (in CAPITAL letter) | តួនាទី<br>Position | លេខទំនាក់ទំនង<br>Contact Number |
|---|---|---|
| | | |

ហត្ថលេខានៃអ្នកទទួលសិទ្ធ Authorized Signature

យើងខ្ញុំសូមបញ្ជាក់ថាទម្ងន់ទាំងអស់ដូចមានក្នុងការប្រកាសខាងលើពិតជាត្រឹមត្រូវប្រាកដមែន។
យើងខ្ញុំសូមបញ្ជាក់ថាជញ្ជីងដែលបានប្រើប្រាស់សម្រាប់ការថ្លឹងទម្ងន់ទំនិញសម្រាប់ផ្ញើតាមនាវានេះពិតជាបាន
បញ្ជាក់និងត្រួតពិនិត្យតាមការតម្រូវរបស់អាជ្ញាធរមានសមត្ថកិច្ច។ ការបញ្ជាក់នេះអាចបង្ហាញជូនបានតាមការស្នើសុំ។

We hereby certify the weights as decalared above to be true and accurate. We certify the scale used for weighting this shipment has been certified and inspected as required by local authorities. Verification is available upon request.

កាលបរិច្ឆេទ Date (dd/mm/yy)